ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
នាយកដ្ឋានរដ្ឋាករ
លេខៈ ០៨៤៤/២០ អគរ/ន.រក

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋាន ក.ប.ប.
ចូល លេខ 742 អ.កបប
ថ្ងៃទី 17 ខែ 12 ឆ្នាំ 2020 ម៉ោង 10:45 AM
បញ្ជូន

ថ្ងៃ ៧ ៤ កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០២០

# ដីការម

សូមគោរពជូន
ឯកឧត្តមអគ្គនាយក
នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | លិខិតលេខ ០៨៣៤/២០ អគរ/ន.រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋានរដ្ឋាករ ស្តីពីសេចក្តីណែនាំអំពីនីតិវិធីអនុវត្តក្នុងការដកសំណាកប្រេងសាំង និងប្រេងម៉ាស៊ូតទៅត្រួតពិនិត្យគុណភាព។ | ០១ច្បាប់ | "ដើម្បីជូនជ្រាប និងសុំកិច្ចសហការ" |
| សរុប | | ០១ច្បាប់ | |

សូមឯកឧត្តមអគ្គនាយក មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

អគ្គនាយករង
និងជាប្រធាននាយកដ្ឋានរដ្ឋាករ

នាយកដ្ឋាន រដ្ឋាករ

សែ សុឃន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
**នាយកដ្ឋានរដ្ឋាករ**
លេខ: ០៩៣៤/២០ អគរ/ន.រក

ថ្ងៃ ៣ុ៨ ២៣៨ ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០២០

**ជម្រាបជូន**
**លោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកា**
**ក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលគេលសិលា**

**កម្មវត្ថុ÷** សេចក្តីណែនាំអំពីនីតិវិធីអនុវត្តក្នុងការដកសំណាកប្រេងសាំង និងប្រេងម៉ាស៊ូតទៅត្រួតពិនិត្យគុណភាព។

**យោង ÷**
- ប្រកាសអន្តរក្រសួងលេខ ៥៧៤ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- លិខិតលេខ ២៧១៧ អគរ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈ និងការដកសំណាកទៅត្រួតពិនិត្យគុណភាព។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកាក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលគេលសិលាជ្រាបថា ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈប្រភេទ៤ (Euro IV) តូចជាង ៥០ភាគលាន (<50 ppm) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១, នាយកដ្ឋានរដ្ឋាករសូមធ្វើការណែនាំអំពីនីតិវិធីអនុវត្តក្នុងការដកសំណាកប្រេងឥន្ធនៈទៅត្រួតពិនិត្យគុណភាពនៅអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប) ដូចខាងក្រោម÷

**១-** ក្រុមហ៊ុនត្រូវដកសំណាកប្រេងសាំង និងប្រេងម៉ាស៊ូតចំនួន ០៣លីត្រ ក្នុងមួយប្រភេទប្រេង ដាក់ចូលប៊ីដុងផ្លាស្ទិក។ សំណាកនេះត្រូវដកយកជាលក្ខណៈវិលជុំពីពោងស្តុកមួយ ទៅពោងស្តុកមួយទៀតនៃមណ្ឌលសន្និធិនាមាត់ច្រកនាំចូល យ៉ាងយូរត្រឹមថ្ងៃទី០៥ ប្រចាំខែនីមួយៗ។

**២-** ក្រុមហ៊ុនត្រូវប្រគល់សំណាកជូនមន្ត្រីគយនិងរដ្ឋាករដែលប្រចាំការតាមមណ្ឌលសន្និធិ ដើម្បីបិទនិងបំពេញទម្រង់ព័ត៌មានសំណាកគំរូទំនិញ រួមទាំងរៀបចំលិខិតអម ដូចមានគំរូភ្ជាប់មកជាមួយ។

**៣-** ក្រុមហ៊ុនទទួលបន្ទុកបញ្ជូនសំណាកទៅអគ្គនាយកដ្ឋាន ក.ប.ប និងបង់កម្រៃសេវាត្រួតពិនិត្យ បើសិនជាមាន។

**៤-** បន្ទាប់ពីទទួលបានលទ្ធផល ក្រុមហ៊ុនត្រូវថតចម្លងលទ្ធផលនេះប្រគល់ជូនមន្ត្រីគយនិងរដ្ឋាករដែលប្រចាំការតាមមណ្ឌលសន្និធិ ដើម្បីរក្សាទុកជាឯកសារ។

ទទួលបានលិខិតនេះ សូមលោកឧកញ៉ា លោក លោកស្រី ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូមលោកឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**អគ្គនាយករង**
**និងជាប្រធាននាយកដ្ឋានរដ្ឋាករ**

សែ_សុឃន

**ចម្លងជូន÷**
- អគ្គនាយកដ្ឋាន ក.ប.ប
  "ដើម្បីជូនជ្រាបនិងសុំកិច្ចសហការ"
- ការិយាល័យគ្រប់គ្រងផលិតផលគេលសិលានិងថាមពល
- មន្ត្រីគយនិងរដ្ឋាករប្រចាំការតាមមណ្ឌលសន្និធិ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

(អមភ្ជាប់លិខិតលេខ ០៩៣៤/២០ អគរ/ន.រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋានរដ្ឋាករ)



(អមភ្ជាប់លិខិតលេខ ០៤៣៨/២០ អគរ/ន.រក ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋានរដ្ឋាករ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**
**នាយកដ្ឋានរដ្ឋាករ**

# លិខិតស្នើសុំធ្វើការវិភាគសំណាកគំរូទំនិញ

លេខ: TOT01-002 អគរ/ន.រក

**I- ក្រុមហ៊ុន (ក្រុមអ្នកទទួលសន្និធិ)** ÷ Total Cambodge (TOT01)

**II- អំពីសំណាកគំរូទំនិញ**

1. **សំណាកគំរូទំនិញទី ១**
   - ឈ្មោះទំនិញ ÷ **ប្រេងសាំង**
   - លេខសម្គាល់សំណាកគំរូ ÷ TOTAL EA-001
   - បរិមាណសំណាកគំរូ ÷ ០៣ លីត្រ ទម្ងន់÷ ០៣ គីឡូក្រាម
2. **សំណាកគំរូទំនិញទី ២**
   - ឈ្មោះទំនិញ ÷ **ប្រេងម៉ាស៊ូត**
   - លេខសម្គាល់សំណាកគំរូ ÷ TOTAL DO-001
   - បរិមាណសំណាកគំរូ ÷ ០៣ លីត្រ ទម្ងន់÷ ០៣ គីឡូក្រាម

**III- តម្រូវការលទ្ធផលនៃការធ្វើវិភាគ**

1. ☑ ការបញ្ជាក់អំពីគុណភាពទំនិញសម្រាប់ការប្រើប្រាស់
2. ☐ ការបញ្ជាក់អំពីសុវត្ថិភាពទំនិញសម្រាប់ការប្រើប្រាស់
3. ☑ ផ្សេងទៀត *(កម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈ)*

**IV- មូលហេតុនៃការស្នើសុំធ្វើការវិភាគ**

1. ☐ ការសង្ស័យលើគុណភាព និង/ឬ សុវត្ថិភាពទំនិញដោយមន្ត្រីគយនិងរដ្ឋាករ
2. ☐ ព័ត៌មានហានិភ័យដែលផ្តល់ដោយអគ្គនាយកដ្ឋាន ក.ប.ប
3. ☑ ផ្សេងទៀត *(ជំរុញអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈ ស្របតាមសារាចររាជរដ្ឋាភិបាល លេខ ០១ សរ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២០ ស្តីពីវិធានការទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ)*

ថ្ងៃ.................................ខែ.....................ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ....................ឆ្នាំ២០២០

**ប្រធាននាយកដ្ឋានរដ្ឋាករ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខ : ៤៧១៧/២០ អ គ រ

ថ្ងៃ ៣ ៨ ១១ ៣ ១៥ ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២០

**ជម្រាបជូន**

**លោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកា**

**ក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលតេលសិលា**

**កម្មវត្ថុ÷** ការអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈ និងការដកសំណាកទៅត្រួតពិនិត្យគុណភាព។

**យោង ÷**
- សារាចរលេខ ០១ សរ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់សាធារណៈ
- ប្រកាសអន្តរក្រសួងលេខ៥៧៤ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីកិច្ចសហការរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- លិខិតលេខ៦០១ សជណ.ដប ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំអនុញ្ញាតជំនួងខ្ពស់លើកលែងការអនុវត្តកម្រិតស្តង់ដាប្រេងឥន្ធនៈប្រភេទ៣ (Euro III) ក្នុងឆ្នាំ២០២០ តាមសំណើរបស់ក្រុមហ៊ុននាំចូលនិងចែកចាយផលិតផលតេលសិលា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកឧកញ៉ា លោក លោកស្រី ជាអគ្គនាយក អគ្គនាយិកាក្រុមហ៊ុនអាជីវកម្មនាំចូល និងចែកចាយផលិតផលតេលសិលាជ្រាបថា ប្រេងសាំង និងប្រេងម៉ាស៊ូតនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ ត្រូវអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈប្រភេទ៤ (Euro IV) តូចជាង ៥០ភាគលាន (<50 ppm)។ ក្រុមហ៊ុនក៏អាចប្រកួតប្រជែងនាំចូលប្រេងសាំង និងប្រេងម៉ាស៊ូត ដោយមានស្តង់ដាកម្រិតស្ពាន់ធ័រដែលមានផ្ទុកក្នុងប្រេងឥន្ធនៈប្រភេទ៥ (Euro V) ផងដែរ។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាកម្រិតស្ពាន់ធ័រនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាកំណត់ឱ្យក្រុមហ៊ុនទាំងអស់ដកសំណាកតាមប្រភេទប្រេងឥន្ធនៈនីមួយៗ ពីពាងស្តុកយកទៅត្រួតពិនិត្យគុណភាពនៅអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប) ជាប្រចាំខែ។ នាយកដ្ឋានរដ្ឋាករត្រូវណែនាំបន្ថែមអំពីនីតិវិធីអនុវត្តក្នុងការដកសំណាកប្រេងឥន្ធនៈទៅត្រួតពិនិត្យគុណភាព។

ទទួលបានលិខិតនេះ សូមលោកឧកញ៉ា លោក លោកស្រី ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ។

សូមលោកឧកញ៉ា លោក លោកស្រី ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា**

**បណ្ឌិត គុណ ញឹម**

**ចម្លងជូន÷**
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “ដើម្បីជូនជ្រាប”
- អគ្គនាយកដ្ឋាន ក.ប.ប “ដើម្បីជូនជ្រាបនិងសុំកិច្ចសហការ”
- នាយកដ្ឋានរដ្ឋាករ “ដើម្បីមុខការ”
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh